# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៨-៩-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៩០៦/៣៨៩ ស្តីពីការបង្កើតគណៈឆ្មបកម្ពុជា ៦៧១២

២០-៩-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៩០៦/៣៩២ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនឯកឧត្តម ឧត្តមសេនីយ៍ត្រី **ឈឿន ចាន់ថន** នៅជាមេបញ្ជាការរងកងពលតូចលេខ ៧០ និងនៅជាមេបញ្ជាការវរសេនាតូចលេខ ១ អង្គរក្សសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ៦៧២៣


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


២៦-៩-២០០៦ -អនុក្រឹត្យលេខ ៦៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧២៤

២៦-៩-២០០៦ -អនុក្រឹត្យលេខ ៦៥៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៧២៦

២៦-៩-២០០៦ -អនុក្រឹត្យលេខ ៦៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧២៧

២៦-៩-២០០៦ -អនុក្រឹត្យលេខ ៦៥៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦៧២៨

២៦-៩-២០០៦ -អនុក្រឹត្យលេខ ៦៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧៣០


### ២. បទបញ្ជា


២០-៩-២០០៦ -បទបញ្ជាលេខ ០២ បប ស្តីពីការគ្រប់គ្រង និង ការត្រួតពិនិត្យ លើការប្រើប្រាស់រណារយន្តកាត់-អារឈើ ៦៧៣២


## III. ការងារបណ្តាក្រសួង

### ទីស្តីការក្រសួងមន្ត្រីក្រសួងពាណិជ្ជកម្ម


០២-៨-២០០៦ -លិខិតបញ្ជាក់លេខ ១៩៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីយ៉ុង អ៊ិនជាសស្ទ្រី ផៅវ័រ អេនជីនារីង** ៦៧៣៣

២២-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ព្រែម ម៉ាល់ធី-ខូអបភើរេសិន** ៦៧៣៥

២៣-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូត្រមុនី ត្រេឌីង** ៦៧៣៧

២៣-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី ឌី អិល អ៊ិនធើណេសិន ណល** ៦៧៣៩

២៤-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម អេស ធី ខបភើរេសិន** ៦៧៤១

២៤-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន**ខូ.ខេ.អេស.អិម លីន លីមីធីត** ៦៧៤៣

២៤-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ព្រះព្រហ្មឱ្យជ័យ** ៦៧៤៥

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រាន វិសេស អ៊ិនធើណេ
សិនណល ប្រាយវេត លីមីធីត** ៦៧៤៧

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យឹម ហួត ត្រេឌីង លីមីធីត** ៦៧៤៩

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.ធី ហាយ ថេក ផៅវ័រ
ស៊ីស្ទឹម អ៊ិន** ៦៧៥១

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បាត់ដំបង ត្រាក់ទ័រ សេនធ័រ** ៦៧៥៣

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៨៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ (ខេមបូឌា) ជី អ៊ី** ៦៧៥៥

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៨៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ែតវ៉ាន ខាឡោ ហ្វ្រេត
(ខេមបូឌា)** ៦៧៥៧

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៨៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ ហ្វ៊ូដ គ្រុប (ខេមបូឌា)** ៦៧៥៩

# ក


២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៨៨ ពណ.នតក ស្តីពីការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **ខូណែល ប្រូស ខូ (ថៃឡែន) អិលធីឌី** " ប្រចាំរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនៅប្រទេសអាមេរិក ៦៧៦១

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធីរោច អ៊ឹមផត អិចផត** ៦៧៦២

២៥-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម អាយ អ អ៊ិនវេស មេន (ខេមបូឌា)** ៦៧៦៤

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៦/៣៤៩

## ស្តីពី

## ការបង្កើតគណៈឆ្មបកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៧៩/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដោយបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគណៈឆ្មបមួយ ដើម្បីប្រមូលផ្តុំឆ្មបទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ និង អមវេជ្ជសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថាឆ្មបក្នុងព្រះរាជក្រឹត្យនេះគឺ នីតិជនដែលមានសញ្ញាប័ត្រឆ្មបចេញដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬសញ្ញាប័ត្រឆ្មបចេញដោយគ្រឹះស្ថានសិក្សាដែលបានទទួលស្គាល់គុណភាពអប់រំដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

ឆ្មបទាំងអស់ដែលប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ត្រូវសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប ។

ចំពោះឆ្មបបុរាណក្រសួងសុខាភិបាលមានគោលនយោបាយដោយឡែក ។

## ជំពូកទី២

## បេសកកម្មរបស់គណៈឆ្មប

**មាត្រា ២.-**

គណៈឆ្មប ត្រូវឃ្លាំមើលការប្រព្រឹត្តទៅនៃបណ្តាគោលការណ៍សីលធម៌ ភាពសុចរិត យុត្តិធម៌ និងភក្តីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រឱ្យបានគង់វង្ស និងមានប្រសិទ្ធភាព ។

គណៈឆ្មប ត្រូវឃ្លាំមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងក្រមសីលធម៌ឆ្មប ។

គណៈឆ្មប ធានាការពារកិត្តិយស និង ឥស្សរភាពរបស់វិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ។

គណៈឆ្មប បំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាគណៈឆ្មប ខេត្ត ក្រុង ដែលសរសេរកាត់ថា **ក.ឆ.ខ.** ក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ ដែលសរសេរកាត់ថា **ក.ឆ.ភ.** និង ក្រុមប្រឹក្សាគណៈឆ្មបជាតិ ដែលសរសេរ កាត់ថា **ក.ឆ.ជ.** ។

## ផ្នែកទី ១

## តួនាទីសីលធម៌

**មាត្រា ៣.-**

គណៈឆ្មបមានបន្ទុករៀបរៀងក្រមសីលធម៌ឆ្មប យកលំនាំតាមលក្ខណៈចាំបាច់នៃវិជ្ជាជីវៈក្នុងការវិវត្តន៍ខ្ជាប់ខ្ជួនខាងបច្ចេកទេសសេដ្ឋកិច្ច និងសង្គមកិច្ចដែលត្រូវធ្វើឱ្យវិវត្តន៍ល្អក្នុងផលប្រយោជន៍របស់អ្នកជំងឺ ។

គណៈឆ្មបតាមឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ សេចក្តីគោរពប្រណិបត្តិ ។

គណៈឆ្មបជាអង្គការស្វយ័ត ។ ការចំណាយ ការផ្គត់ផ្គង់ប្រាក់កាស ម្ចាស់ការខ្លួនឯង ធានាឥស្សរភាពការពារផលប្រយោជន៍សីលធម៌វិជ្ជាជីវៈ ។

## ផ្នែកទី ២

## តួនាទីគ្រប់គ្រងរដ្ឋបាល

**មាត្រា ៤.-**

ការចាត់ចែងអំណាចត្រូវអនុលោមតាមបញ្ជាគណៈឆ្មប ។

គណៈឆ្មបត្រូវរៀបចំធ្វើ និង ថែរក្សាទុកជាប្រចាំនូវបញ្ជីរាយនាមឆ្មប ដែលបានចុះឈ្មោះបំពេញលក្ខខណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

កាតព្វកិច្ចនៃការចុះឈ្មោះ ក្នុងបញ្ជីរាយនាមឆ្មប គឺដើម្បីបំពេញការរៀបចំថែទាំព្យាបាលជំងឺ ។

គណៈឆ្មបជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលមានមុខងារតាមឃ្លាំមើលលក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនេះ ។

## ផ្នែកទី ៣

## តួនាទីសម្រេចសេចក្តីតាមបែបតុលាការ

**មាត្រា ៥.-**

បណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនៃមុខវិជ្ជាជីវៈរបស់ឆ្មបណាមួយទៅគណៈឆ្មប មិនមែនជាឧបសគ្គក្នុងការធ្វើបណ្តឹងចំពោះការប្រព្រឹត្តខុសឆ្គងនេះ ទៅតុលាការឡើយ ។

## ផ្នែកទី ៤

## តួនាទីពិភាក្សាផ្តល់យោបល់

**មាត្រា ៦.-**

គណៈឆ្មបអាចត្រូវបានកោះហៅឱ្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិជ្ជាជីវៈឆ្មបទាំងឡាយ ។

## ផ្នែកទី៥

## តួនាទីជួយសង្គ្រោះគ្នាទៅវិញទៅមក

**មាត្រា ៧.-**

ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះមានបច្ច័យដល់ឆ្មប និងគ្រួសាររបស់គេ ។ ការជួយសង្គ្រោះគ្នាបានរៀបចំតាមបែបបទដូចតទៅ ÷

- គណៈឆ្មបត្រូវមានក្នុងថវិការបស់ខ្លួន ប្រាក់បម្រុងសម្រាប់ជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ប្រាក់បម្រុងជាជំនួយភ្លាមៗ ក្នុងករណីសមរម្យដល់គ្រួសារឆ្មប ដែលត្រូវរងទុក្ខលំបាក
- គណៈឆ្មបត្រូវមានគណៈកម្មការមួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគមឆ្មបកម្ពុជាម្នាក់ជាសមាជិក
- គណៈកម្មការនេះ ចាត់ចែងឱ្យមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់វិភាគទានពីឆ្មប

ម្នាក់ៗដែលចុះឈ្មោះ ក្នុងគណៈឆ្មប ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

## ផ្នែកទី១

## ក្រុមប្រឹក្សាគណៈឆ្មបថ្នាក់ខេត្ត ក្រុង (ក.ឆ.ខ.)

**មាត្រា ៨.-**

ក.ឆ.ខ. ត្រូវបង្កើតនៅតាមខេត្ត ក្រុងនីមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំពោះខេត្ត ក្រុង ដែលមានចំនួនឆ្មបតិចជាងម្ភៃ (២០)នាក់ ត្រូវបញ្ចូលទៅខេត្តដែលនៅជិតជាងគេដើម្បីបង្កើតក្រុមប្រឹក្សាគណៈឆ្មប ។

**មាត្រា ៩.-**

ក.ឆ.ខ. ត្រូវមានសមាជិកពេញសិទ្ធិចំនួនប្រាំបួន (០៩)រូប និងសមាជិកជំនួសចំនួនប្រាំបួន(០៩)រូប ក្នុងករណីដែលចំនួនឆ្មបដែលបានចុះឈ្មោះក្នុងបញ្ជីមានមិនលើសពីមួយរយ (១០០) នាក់ ។ ចំនួននេះនឹងឡើងទៅដល់ដប់មួយ (១១), ដប់ប្រាំ (១៥), ដប់ប្រាំបួន(១៩) ឬ ម្ភៃមួយ (២១)រូប បើសិនចំនួនឆ្មបនៅក្នុងបញ្ជីមានលើសពីមួយរយ(១០០), ប្រាំរយ(៥០០), មួយពាន់ (១.០០០) ឬ ពីរពាន់ (២.០០០) នាក់ ។

**មាត្រា ១០.-**

ក.ឆ.ខ. ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយបណ្តាឆ្មបដែលបានចុះឈ្មោះ នៅក្នុងបញ្ជីរបស់ ក.ឆ.ខ. សម្រាប់រយៈពេលប្រាំមួយ (០៦)ឆ្នាំ ។

សមាជិកចប់អាណត្តិ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សា ធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួននៅក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិកក្រុមប្រឹក្សា ។ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ក្នុងករណីដែលចំនួនសមាជិកផ្លាស់ប្តូរមានចំនួនចែកមិនដាច់ ។

សមាសភាពការិយាល័យរបស់ក.ឆ.ខ. រួមមាន ប្រធានក្រុមប្រឹក្សាមួយរូបអនុប្រធានមួយ (០១) រូបអគ្គលេខាធិការ មួយ (០១ )រូប ហិរញ្ញិកមួយ (០១ )រូប និងសមាជិកប្រាំ (០៥ )រូប ។

**មាត្រា ១១.-**

ក.ឆ.ខ. បំពេញការងារនៅក្នុងក្របខ័ណ្ឌខេត្ត ក្រុងរបស់ខ្លួន និង ក្រោមការត្រួតពិនិត្យរបស់គណៈឆ្មបជាតិ ចំពោះសមត្ថកិច្ចទូទៅទាំងឡាយ ដែលមានចែងក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ។ ក.ឆ.ខ. សម្រេចអារកាត់ក្នុងការចុះឈ្មោះឆ្មបដែលបានបំពេញល័ក្ខខ័ណ្ឌតាម មាត្រា៣ ជំពូកទី១ និង មាត្រា៦ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ នៅក្នុង

បញ្ជីរបស់គណៈឆ្មប ។ គ.ឆ.ខ. មិនប្រកាន់ភេទ ជំនឿសាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬ ស្ថានភាព ឯទៀតរបស់សមាជិកខ្លួនឡើយ ។

**មាត្រា ១២.-**

គ.ឆ.ខ. ពុំមានអំណាចដាក់វិន័យទេ បើមានពាក្យប្តឹងចំពោះឆ្មបដែលស្ថិតក្រោម សមត្ថកិច្ច របស់ខ្លួន គ.ឆ.ខ. ត្រូវបញ្ជូនបណ្តឹងនោះទៅក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

**មាត្រា ១៣.-**

ប្រធានតំណាងឱ្យ គ.ឆ.ខ. នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។

**មាត្រា ១៤.-**

ការប្រជុំនៃក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុង នឹងមិនធ្វើជាសាធារណៈឡើយ ។ កាលណាមាន សម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាពសម្រេច ។ ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ត្រូវបានអញ្ជើញ ចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា គ្រាន់តែមានសម្លេងពិគ្រោះយោបល់ ។ គ.ឆ.ខ. អាចអញ្ជើញទីប្រឹក្សាច្បាប់ មួយរូបចូលរួមក្នុងអង្គប្រជុំ ។

**មាត្រា ១៥.-**

ឆ្មបនៅតាមបណ្តាខេត្ត ក្រុង ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជី ដែលកាន់កាប់ជាប្រចាំដោយ ក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុងពាក់ព័ន្ធ ។ អាចចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប តែចំពោះឆ្មបដែលមានសញ្ញាប័ត្រ ឆ្មប ចេញដោយក្រសួងសុខាភិបាលឬសញ្ញាប័ត្រចេញដោយគ្រឹះស្ថានសិក្សា ដែលទទួលស្គាល់ដោយគណៈកម្មាធិការ ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង បានបំពេញល័ក្ខខ័ណ្ឌ ច្បាប់ និង ក្រមសីលធម៌ដែលបានកំណត់ ។

ឆ្មបអាចចុះឈ្មោះបានតែនៅក្នុងបញ្ជីនៃខេត្ត ក្រុងដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ ។

**មាត្រា ១៦.-**

គ.ឆ.ខ. ត្រូវសម្រេចលើការសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរបី(០៣)ខែ ដោយគិតចាប់តាំងពីថ្ងៃ ទទួលពាក្យដែលមានឯកសារគ្រប់គ្រាន់ ។

ក្នុងរយៈពេលមួយសប្តាហ៍យ៉ាងយូរក្រោយការសម្រេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិត អនុសាសន៍ទៅឆ្មបសាមី ។ បើមានការបដិសេធលើសំណើរសុំចុះឈ្មោះ គ.ឆ.ខ. ត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ ជាលាយលក្ខណ៍អក្សរ ។

ការអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មបខេត្ត ក្រុងនីមួយៗ ត្រូវជូនដំណឹងយ៉ាងយូរពីរ សប្តាហ៍ទៅអាជ្ញាធរ ខេត្ត ក្រុង ទៅព្រះរាជអាជ្ញានៃខេត្ត ក្រុងពាក់ព័ន្ធ និង ទៅក្រុមប្រឹក្សាគណៈឆ្មបជាតិ ។

**មាត្រា ១៧.-**

ក្រោយពីបានអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មបខេត្ត ក្រុង ដែលខ្លួនកំពុងប្រកបវិជ្ជាជីវៈ

ឆ្មបអាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនៅខេត្ត ក្រុងដែលខ្លួនបានចុះឈ្មោះប៉ុណ្ណោះ ។ ក្នុងករណីមានការផ្លាស់ប្តូរលំនៅស្ថានវិជ្ជាជីវៈទៅក្រៅខេត្ត ក្រុង ដែលខ្លួនបានសុំចុះឈ្មោះ ឆ្មបត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់ និងត្រូវធ្វើពាក្យសុំចុះឈ្មោះសារជាថ្មី ទៅក្រុមប្រឹក្សាខេត្ត ក្រុងដែលខ្លួនទៅរស់នៅប្រកបវិជ្ជាជីវៈ ។

**មាត្រា ១៨.-**

ក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុង ត្រូវទទួលបណ្តឹងជំទាស់ពីក្រុមប្រឹក្សាជាតិ សមាគមឆ្មប រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការ ឬឆ្មបណាម្នាក់ ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប រួចហើយធ្វើរបាយការណ៍ផ្ញើជូនគណៈឆ្មបជាតិ ។

## ផ្នែកទី២

## ក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ (ក.ឆ.ភ.)

**មាត្រា ១៩.-**

ការបែងចែកភូមិភាគសម្រាប់គណៈឆ្មបកម្ពុជានេះ ត្រូវបានរៀបចំដូចខាងក្រោម ÷

ភូមិភាគ ១ : រួមមានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ ។

ភូមិភាគ ២ : មានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង ។

ភូមិភាគ ៣ : មានខេត្តតាកែវ កំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប មានទីតាំងនៅខេត្តកំពត ។

ភូមិភាគ ៤ : មានខេត្តស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង ។

ភូមិភាគ ៥ : មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង ស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

**មាត្រា ២០.-**

**ក.ឆ.ភ.** មានតួនាទីជាក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋម មានសមាជិកពេញសិទ្ធិ ចំនួនប្រាំបួន (០៩)រូប និង សមាជិកជំនួសចំនួនប្រាំបួន (០៩) រូប បោះឆ្នោតជ្រើសរើសក្នុងចំណោម **ក.ឆ.ខ.** ក្នុងភូមិភាគ។ **ក.ឆ.ខ.** នីមួយៗ ត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យបានយ៉ាងតិចមួយ (០១) រូបពេញសិទ្ធិ និងមួយ (០១) រូបជាជំនួស ចំនួនអាសនៈដែលនៅសល់ ត្រូវបែងចែកទៅខេត្ត ក្រុង ដោយផ្អែកទៅលើចំនួនឆ្មប ដែលបានចុះឈ្មោះជាសមាជិកក្រុមប្រឹក្សាភូមិភាគ ។សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេល ០៦ឆ្នាំ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សា

ធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងសមាសភាពនៃការិយាល័យ នៅក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិកក្រុមប្រឹក្សា ។ សមាជិកជំនួសត្រូវចូលជំនួយសមាជិកពេញសិទ្ធិ នៅពេលដែលសមាជិកនេះអវត្តមានដោយមូលហេតុអ្វីក៏ដោយ ។

ការិយាល័យមានសមាសភាព : ប្រធានមួយ (០១) រូប អនុប្រធានមួយ (០១) រូប អគ្គលេខាធិការមួយ (០១) រូប ហេរញ្ញិកមួយ (០១) រូប និង សមាជិកប្រាំ (០៥ ) រូប ។

**មាត្រា ២១.‐**

ប្រធាន **គ.ធ.ខ.** ប្រធាន **គ.ធ.ភ.** និងអគ្គលេខាធិការនៃក្រុមប្រឹក្សាទាំងនេះមិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

**មាត្រា ២២.‐**

អង្គប្រជុំ **គ.ធ.ភ.** ត្រូវបានចូលរួមក្នុងឋានៈជាអនុប្រធាន និងជាអ្នកពិគ្រោះយោបល់ដោយ ÷

-តំណាងឱ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគ

-ទីប្រឹក្សាច្បាប់មួយរូប ចាត់តាំងដោយប្រធានតុលាការនៃខេត្ត ក្រុងនោះ

-ធ្មបការងារមួយរូប បើមានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ។

**មាត្រា ២៣.‐**

នៅក្នុងក្របខ័ណ្ឌគណៈធ្មបភូមិភាគ **គ.ធ.ភ.** អនុវត្តន៍ការងាររបស់ខ្លួនតែទៅលើសមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ ។

**គ.ធ.ភ.** អាចទទួលពាក្យប្តឹងជំទាស់ពី **គ.ធ.៩.** **គ.ធ.ខ.** សមាគមធ្មប រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាល អាជ្ញាធរខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ឬ សាមីធ្មប ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈធ្មប ។

**គ.ធ.ភ.** ត្រូវពិនិត្យសម្រេចនៅក្នុងរយៈពេលប្រាំមួយ (០៦) ខែយ៉ាងយូរ ក្រោយបានទទួលពាក្យប្តឹង ។ បើមិន ដូច្នេះទេ **គ.ធ.៩.** អាចបញ្ជូនពាក្យប្តឹងនេះទៅ **គ.ធ.ភ.** ណាមួយផ្សេងទៀតដែលបានជ្រើសរើស ។

**មាត្រា ២៤.‐**

ធ្មបដែលកំពុងបម្រើការនៅក្នុងសេវាសាធារណៈ ហើយបានសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈធ្មបនឹងអាចបកស្រាយចំពោះមុខ **គ.ធ.ភ.** បានចំពោះសកម្មភាពក្នុងមុខងារសាធារណៈរបស់ខ្លួន តែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ឬ តាមរយៈព្រះរាជអាជ្ញាអមតុលាការតែប៉ុណ្ណោះ ។

**មាត្រា ២៥.‐**

ការដាក់វិន័យត្រូវធ្វើឡើងនៅចំពោះមុខធ្មបសាមី ។ ធ្មបសាមីអាចមានអ្នកការពារដែលជាធ្មប

ឬ ជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ បើឆ្មបសាមីមិនព្រមចូលខ្លួនមកបំភ្លឺ ក.ឆ.ក. តាមការអញ្ជើញចំនួនបី (០៣) លើក ដោយគ្មានមូលហេតុច្បាស់លាស់ ក.ឆ.ក. នឹងអនុវត្តតាមចំណុចទី៤ ក្នុងមាត្រា២៧ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ២៦ .-**

ក.ឆ.ក. ត្រូវមានបញ្ជីកត់ត្រានូវរាល់ការប្រជុំដាក់វិន័យ ។ ក.ឆ.ក. ត្រូវធ្វើកំណត់ហេតុត្រឹមត្រូវ ដោយមានការបញ្ជាក់ និងចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជនដែលត្រូវចោទសួរនោះផង ។

**មាត្រា ២៧.-**

ក.ឆ.ក.ដោយមានការចូលរួមពីផ្នែកវិន័យនៃក.ឆ.ខ.អាចដាក់វិន័យដល់សមាជិកដូចខាងក្រោម÷

១- ការព្រមាន។

២-សេចក្តីបន្ទោសដោយកត់ទុកនៅក្នុងឯកសារផ្ទាល់ខ្លួន។

៣-ហាមប្រកបវិជ្ជាជីវៈមួយរយៈពេលមិនលើសពីបី (០៣) ឆ្នាំ ឬ ជាអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬ ជាទូទៅ នៃមុខងារវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រដែលរដ្ឋទទួលស្គាល់ ។

៤-ការលុបឈ្មោះចេញពីបញ្ជីគណៈឆ្មប។

ឆ្មបដែលត្រូវលុបឈ្មោះចេញពីក្នុងបញ្ជីគណៈឆ្មប មិនអាចសុំចុះឈ្មោះនៅកន្លែងណាផ្សេងទៀតបានឡើយ ។

សេចក្តីដែលបានសម្រេចចុងក្រោយដែលបានលើកឡើង ត្រូវតែផ្សព្វផ្សាយទៅគ្រប់ ក.ឆ.ខ. ព្រមទាំងទៅ ក.ឆ.ជ. ។ ការសម្រេចរបស់ ក.ឆ.ក. ត្រូវតែមានហេតុផលច្បាស់លាស់។

**មាត្រា ២៨.-**

ក្រោយបានទទួលវិន័យហាមប្រកបវិជ្ជាជីវៈអស់រយៈកាលបី (០៣) ឆ្នាំយ៉ាងតិចមក ឆ្មបដែលទទួលវិន័យ អាចទទួលការលើកលែងវិន័យពីក្រុមប្រឹក្សាគណៈឆ្មប ដែលបានដាក់វិន័យដល់ខ្លួន ។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយឆ្មបសាមី ។ កាលណាលិខិតស្នើសុំលើកលែងវិន័យនេះ ត្រូវបានបដិសេធក្រោយពីបានធ្វើការពិនិត្យពិចារណាស៊ីជម្រៅមក ការស្នើសុំលើកលែងវិន័យសារជាថ្មី នឹងអាចធ្វើទៅបានតែក្នុងរយៈកាល មួយ (០១)ឆ្នាំ ទៅមុខទៀត ។

ចំពោះវិន័យអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬ ជាទូទៅនៃមុខងារវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ដែលរដ្ឋទទួលស្គាល់ មិនអាចស្នើសុំលើកលែងបានទេ។

**មាត្រា ២៩.-**

ការអនុវត្តវិន័យរបស់ឆ្មប មិនមែនជាឧបសគ្គរាំងដល់ការអនុវត្តការដាក់វិន័យខាងរដ្ឋបាល ឬ តុលាការឡើយ ។

## ផ្នែកទី៣
## ក្រុមប្រឹក្សាគណៈឆ្មបជាតិ (គ.ឆ.ជ.)

**មាត្រា ៣០.-**

**គ.ឆ.ជ.** ត្រូវបានជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេលប្រាំមួយ(០៦)ឆ្នាំ បែងចែកដូចខាងក្រោម ÷

-តំណាងឱ្យខេត្ត ក្រុង នីមួយៗ ចំនួនមួយ (០១) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមសមាជិកគណៈឆ្មប ខេត្ត ក្រុងនោះ អ្នកជាប់ឆ្នោតត្រូវបានតែងតាំងដោយប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង

-តំណាងឱ្យរាជធានីភ្នំពេញចំនួនពីរ (០២) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមសមាជិកគណៈឆ្មបរាជធានីភ្នំពេញ ។ អ្នកជាប់ឆ្នោតត្រូវបានតែងតាំង ដោយប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ

- តំណាងឱ្យអង្គភាពថ្នាក់កណ្តាលចំនួនប្រាំ (០៥) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោម សមាជិកឆ្មបថ្នាក់កណ្តាល និងបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-តំណាងឱ្យសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រចំនួនមួយ(០១)រូប ជ្រើសរើសដោយការបោះឆ្នោត តែងតាំងដោយសាកលវិទ្យាធិការ ។

**មាត្រា ៣១.-**

**គ.ឆ.ជ.** ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួនមួយភាគបី (១/៣) ក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរសមាជិកមួយភាគបី (១/៣) ម្តងៗ ក្រុមប្រឹក្សាគណៈឆ្មបជាតិ ត្រូវធ្វើការជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួនសម្រាប់ពីរ (០២) ឆ្នាំម្តង ។

ការិយាល័យរបស់ក្រុមប្រឹក្សាគណៈឆ្មបជាតិកម្ពុជា រួមមាន : ប្រធានក្រុមប្រឹក្សាមួយ (០១)រូប អនុប្រធានចំនួនពីរ (០២)រូប អគ្គលេខាធិការមួយ (០១)រូប អគ្គលេខាធិការរងមួយ(០១)រូប ហិរញ្ញិក មួយ (០១)រូប និងហេរញ្ញិករងមួយ (០១) រូប ។ ប្រធាន និង សមាជិក **គ.ឆ.ជ.** ដែលចេញពីតំណែងអាចឈរឈ្មោះឱ្យគេជ្រើសរើសសារជាថ្មីបាន ។

**មាត្រា ៣២.-**

**គ.ឆ.ជ.** មានជំនួយការជាឆ្មប ចំនួនពីរ (០២) រូប តំណាងឱ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មួយ (០១)រូប និងតំណាងឱ្យរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈមួយ (០១) រូប មានសម្លេងពិគ្រោះយោបល់ ។

**មាត្រា ៣៣.-**

**គ.ឆ.ជ.** មានផ្នែកវិន័យមួយដែលមានសមាជិក(០៧)រូប ដឹកនាំដោយប្រធានមួយ (០១) រូប ជ្រើសតាំងក្នុងចំណោមសមាជិកប្រាំពីរ (០៧) រូបនេះ ។ សមាជិកផ្នែកវិន័យ ត្រូវបានជ្រើសរើសតាមការបោះឆ្នោតក្នុងចំណោមសមាជិកការិយាល័យនៃក្រុមប្រឹក្សា **គ.ឆ.ជ.** ។

ផ្នែកវិន័យមានភារកិច្ចដូចបានកំណត់ក្នុងមាត្រា ២៣ និងមាត្រា ២៧ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣៤.-**

បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួនមួយភាគបី ១/៣ របស់ខ្លួន **គ.ធ.៩.** ត្រូវធ្វើការជ្រើសតាំងផ្នែកវិន័យសារជាថ្មី ។

**មាត្រា ៣៥.-**

**គ.ធ.៩.** បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួន ពេលបំពេញបេសកកម្ម ដូចមានចែងនៅក្នុងមាត្រា ២ នៃព្រះរាជក្រឹត្យនេះ ។

**គ.ធ.៩.** ឃ្លាំមើលជាអាទិ៍ ការគោរពអនុវត្តតាម របស់សមាជិកនៃគណៈឆ្មបទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយដែលបានកំណត់នៅក្នុងក្រមសីលធម៌ឆ្មប ។

**គ.ធ.៩.** សហការជាមួយ **គ.ធ.ខ.** ធ្វើការសិក្សាដោះស្រាយនូវបញ្ហាសុត្រស្បាញទាំងឡាយដែលពាក់ព័ន្ធទៅនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់ឆ្មប ។

**គ.ធ.៩.** បំពេញការងារនេះតាមរយៈផ្នែក និងគណៈកម្មការទាំងឡាយរបស់ខ្លួន និងពិនិត្យសិក្សានូវបណ្តាបញ្ហា ឬ គម្រោងការណ៍ទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

**មាត្រា ៣៦ .-**

**គ.ធ.៩.** ត្រូវកំណត់អំពីចំនួនទឹកប្រាក់វិភាគទានឯកភាពមួយ ដែលសមាជិកម្នាក់ៗត្រូវបង់នៅពេលសុំចុះឈ្មោះ និងត្រូវបង់ប្រចាំឆ្នាំ ។

**គ.ធ.៩.** ត្រូវកម្រិតផងដែរ នូវចំនួនវិភាគទានដែល **គ.ធ.ខ.** ត្រូវបង់ជូនទៅ **គ.ធ.៩.** ទៅ **គ.ធ.គ.** និង ត្រូវរក្សាទុកនៅក្នុង **គ.ធ.ខ.** ដើម្បីជាទាំចំណាយក្នុងការបំពេញការងារជាទូទៅ ។ ការបង់វិភាគទានគឺជាកាតព្វកិច្ច របស់សមាជិកម្នាក់ៗ ។

**គ.ធ.៩.** គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈឆ្មប និងអាចបង្កើត ឬ ឧបត្ថម្ភដល់វណ្ណកម្មទាំងឡាយ ដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈឆ្មប ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

**គ.ធ.៩.** ត្រួតពិនិត្យការគ្រប់គ្រងរបស់**គ.ធ.ខ.**និង**គ.ធ.គ.** ។ **គ.ធ.ខ.** ត្រូវរាយការណ៍ជូន**គ.ធ.៩.** ជាមុន និងចម្លងជូនទៅ **គ.ធ.គ.** ចំពោះការបង្កើតអង្គការទាំងឡាយរបស់ខ្លួន ព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

**មាត្រា ៣៧.-**

**គ.ធ.៩.** ត្រូវបង្កើតគណៈកម្មការសម្រាប់ចាត់ចែងហិរញ្ញវត្ថុ និងធ្វើសវនកម្មផ្ទៃក្នុង ។ សមាជិកនៃ គណៈកម្មការនេះត្រូវជ្រើសរើសដោយ **គ.ធ.៩.** ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យ នៃ ក្រុមប្រឹក្សា និងផ្នែកវិន័យ ។

ក្នុងបំណាច់ឆ្នាំនីមួយៗ គណៈកម្មការនេះ ត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូន គ.ឆ.ជ. ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨.-**

ក្នុងអាណត្តិទី ១ នេះ សមាសភាព គ.ឆ.ជ. ត្រូវបានជ្រើសតាំង និងឯកភាពដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីដំណើរការឱ្យមានប្រសិទ្ធភាព ។

ក្នុងអំឡុងពេលប្រាំមួយ ( ០៦ ) ឆ្នាំដំបូងនៃអាណត្តិទី ១ សមាសភាពការិយាល័យរបស់គ.ឆ.ខ. គ.ឆ.គ. ត្រូវបានជ្រើសតាំងដោយសហភាគៈរបស់ខ្លួន និងទទួលស្គាល់ដោយ គ.ឆ.ជ. ។

**មាត្រា ៣៩.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវតែងតាំងក្រុមការងារមួយជាមណ្ដោះអាសន្នដើម្បីរៀបចំដំណើរការបង្កើតគណៈឆ្មបកម្ពុជា ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១.-**

សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសំបន្ទាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣ក.០៦០៩.៤១៣

លេខ : ៣៧០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជីនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៦/៣៩២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនឯកឧត្តម ឧត្តមសេនីយ៍ត្រី **ឈឿន ចាន់ថន** អត្តលេខ ០០៣៣៦១ នៅជាមេបញ្ជាការរងកងពលតូចលេខ ៧០ និងនៅជាមេបញ្ជាការវរៈសេនាតូចលេខ១ អង្គរក្សសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ។

**មាត្រា២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ជករ**

**ជា ស៊ីម**

៣៤៧.០៦០៩.៤១៦

លេខ: ៣៧៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៦៥៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
៙
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅឃុំត្រើយស្លា ឃុំស្វាយប្រទាល ស្រុកស្អាង និងនៅវត្តពាមមង្គល ឃុំរការកោង ១ ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **ឈួន** | **ឈុំ** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១១៤.៩៤០.០០០ រៀល |
| ២-លោកជំទាវ | **ណាល់** | **សុខអៀន** | ភរិយា ឧកញ៉ា **ឡុង ហ៊ីង** | ថវិកាចំនួន ២៤.០២០ ដុល្លារ |
| ៣-លោកស្រី | **ធៀន** | **ឡេង** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ៤-ឧបាសក | **នង** | **សេង** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១៧.៥០០ ដុល្លារ |
| ៥-ឧបាសិកា | **ជៀម** | **នាង** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១៦.៩៥១ ដុល្លារ |
| ៦-អ្នកស្រី | **ចេង** | **ស្រួយ** | នៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.១៥០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **តាង** | **សេងហួរ** | ទេសរដ្ឋមន្ត្រី | ថវិកាចំនួន ៨.៧០០ ដុល្លារ |
| ២-ឧកញ៉ា | **ចាស់** | **ទីរី** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | ថវិកាចំនួន ៦.២៥០ ដុល្លារ និង ៥.០០០.០០០ រៀល |
| ៣-អ្នកស្រី | **ឌួច** | **សុខខេង** | អាជីវករក្រុងភ្នំពេញ | ថវិកាចំនួន ៦.៨០០ ដុល្លារ |
| ៤-លោក | **តឹក** | **សាលី** | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | ថវិកាចំនួន ៥.២០០ ដុល្លារ និង ៧.៧៨០.០០០ រៀល |

| | | | | | |
|---|---|---|---|---|---|
| ៥-លោក | **ចំនួ** | **សុខា** | នៅរាជធានីភ្នំពេញ | ថវិកាចំនួន ៥.៣០០ | ដុល្លារ |
| ៦-លោក | **ហ៊ុន** | **អៀ** | អាជីវករនៅរាជធានីភ្នំពេញ | ថវិកាចំនួន ៦.៦០០ | ដុល្លារ |
| ៧-ឧបាសក | **ស៊ុំ** | **អ៊ូក** | គណៈកម្មការវត្ត | ថវិកាចំនួន ៨.០០០ | ដុល្លារ |
| ៨-ឧបាសក | **ហុក** | **ប្រ៊ុយ** | គណៈកម្មការវត្ត | ថវិកាចំនួន ៧.០០០ | ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦*

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៥៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះសង្ឃ ចំនួន០២ព្រះអង្គ ដែលមានស្នាព្រះហស្តល្អ ក្នុងការដឹកនាំកសាង និង អភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា និងសង្គមកិច្ច ដូចមានរាយព្រះនាមខាងក្រោម :-

១-ព្រះតេជគុណ **ឈួន ប៉ុយ** គ្រូសូត្រឆ្វេង វត្តពាមមង្គល ឃុំរការកោង ១ ស្រុកមុខកំពូល ខេត្តកណ្តាល

២-ព្រះតេជគុណ **នួន នួនរាន** គ្រូសូត្រស្តាំ វត្តពាមមង្គល ឃុំរការកោង ១ ស្រុកមុខកំពូល ខេត្តកណ្តាល

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៥៥ អនក្រ-ទស

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ មេបញ្ជាការ កងទ័ពជើងគោក

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាង អគារសិក្សា ចំនួន០២ខ្នង អណ្តូងទឹក និងសួនកុមារ ០១កន្លែង នៅតំបន់អភិវឌ្ឍន៍ អន្លង់ក្រពើ ចំណាយអស់ទឹកប្រាក់សរុបចំនួន ១០០.០០០ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១-លោក JHON NA
២-លោក **គាំ សារុន**
៣-លោក **អ៊ិត ណុប**
៤-លោក **ជា យូហេង**
៥-លោក **គាំ អ៊ិន**
៦-លោកស្រី **ឃីម ជាឡា**
៧-លោក **សូរ្យ សិទ្ធិ**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៧៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការ កងទ័ពជើងគោក

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយទាហាន និងនាយទាហានរង ចំនួន ១៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

១-លោក ឧត្តមសេនីយ៍ត្រី **ហ៊ឹម រដ្ឋា**
២-លោក វរសេនីយ៍ឯក **អ៊ិុង ណារិទ្ធ**
៣-លោក វរសេនីយ៍ឯក **ហេង សាក់សំគា**
៤-លោក វរសេនីយ៍ឯក **ឡេង លីម**
៥-លោក វរសេនីយ៍ឯក **ស៊ុខ សាយ**
៦-លោក វរសេនីយ៍ឯក **រស់ ទាសនា**
៧-លោក វរសេនីយ៍ឯក **ជា វណ្ណារិទ្ធ**
៨-លោកស្រី វរសេនីយ៍ទោ **វណ្ណ ស៊ុគី**
៩-លោក វរសេនីយ៍ទោ **គង់ សារ៉ាន់**
១០-លោក វរសេនីយ៍ទោ **ឈុន ម៉ៅ**
១១-លោក វរសេនីយ៍ទោ **លីម គុណឧត្តម**
១២-លោក វរសេនីយ៍ត្រី **ឡុង ច័ាន់**

១៣-លោក វរសេនីយ៍ត្រី **ជួប សុគន្ធ**
១៤-លោក វរសេនីយ៍ត្រី **ឆន់ ប៊ុនធឿន**
១៥-លោក អនុសេនីយ៍ឯក **តុល សារិន**
១៦-លោក អនុសេនីយ៍ត្រី **គង់ គិរុណា**
១៧-លោក ព្រិន្ទបាលឯក **ហុង យឿន**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៤៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១០រូប ដែលបានបរិច្ចាគធនធានជួយសាងសង់អគារ ចំនួន០៥ខ្នង នៅទីបញ្ជាការដ្ឋានយោធភូមិភាគទី៤ ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ ទឹកប្រាក់ចំនួន ១០.១០០ ដុល្លារ

២-លោកជំទាវ **មាស សន** សមាជិកកាកបាទក្រហមខេត្តសៀមរាប ទឹកប្រាក់ចំនួន ១២.០០០ ដុល្លារ

៣-លោកស្រី **សុខ វិសែនសុផល** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១០.២០០ ដុល្លារ

៤-លោកស្រី **ឆ្នុក គីមឌុន** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១០.៣៣០ ដុល្លារ

៥-លោក **ជា ហួត** ប្រធានក្រុមហ៊ុន **សំរោងទួត** ទឹកប្រាក់ចំនួន ១០.៦០០ ដុល្លារ

៦-វរសេនីយ៍ត្រី **អ៊ុំ ឆួង** នាយរងការិយាល័យទី២ យោធភូមិភាគទី៤ ទឹកប្រាក់ចំនួន ១០.២០០ ដុល្លារ

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **សុខ ស៊ីថា** ប្រធានក្រុមហ៊ុន ហាប់ ហ្គាង ឌីវេឡុបមេន ភី ធី អិលធីឌី ទឹកប្រាក់ចំនួន ៥.១០០ ដុល្លារ

**គ_មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-ឧត្តមសេនីយ៍ត្រី **នួន តា** នាយករងទីចាត់ការ ការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

២-លោក **លី ម៉ាន់ហូ** ប្រធានក្រុមហ៊ុន ជេម អង្គរ ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

៣-លោក **ចាក់ វេង** អាជីវករ ខេត្តសៀមរាប ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៦*

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ០៤ បប

ភ្នំពេញ, ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០០៦

## បទបញ្ជា
## ស្តីពី
## ការគ្រប់គ្រង និង ការត្រួតពិនិត្យ លើការប្រើប្រាស់រណារយន្តកាត់-អារឈើ

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការលុបបំបាត់ទាំងស្រុងនូវអំពើអនាធិបតេយ្យកាប់បំផ្លាញព្រៃឈើ ជាពិសេស ដើម្បីទប់ស្កាត់ បង្ក្រាប និង លុបបំបាត់ ការកាប់រានព្រៃឈើ ការឈូសឆាយដីព្រៃឈើគ្រប់ប្រភេទ (ដីព្រៃឈើ ដីព្រៃលិចទឹក និងដីព្រៃក្នុងតំបន់ការពារធម្មជាតិ) ដើម្បីហ៊ុំព័ទ្ធយកដីធ្វើជាកម្មសិទ្ធិ ដែលជាប្រភពដ៏គ្រោះថ្នាក់បំផុតនាំឱ្យមានទំនាស់ដីធ្លី ក៏ដូចជាអំពើពុករលួយផងដែរនោះ **រាជរដ្ឋាភិបាល ចាំបាច់ដាក់ចេញនូវបទបញ្ជាបន្ថែមជាបន្ទាន់ឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អនុវត្តដូចខាងក្រោម :**

១- រាល់ការនាំចូល ការប្រើប្រាស់ ការធ្វើសន្និធិ ការរក្សាទុក ការលក់ដុំ ឬលក់រាយ ការដឹកជញ្ជូន ការទិញដូរ និងការធ្វើអំណោយនូវរណារយន្តកាត់-អារឈើ សម្រាប់ប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ ឬឯកជន ត្រូវមានការអនុញ្ញាត និងវាយតម្លៃ ភាពសមស្រប ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ)។ ក្នុងករណីប្រើប្រាស់រណារយន្តកាត់-អារឈើ ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ត្រូវមានគោលការណ៍ឯកភាពពីក្រសួងបរិស្ថាន មុនពេលដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) សម្រេចផ្តល់ការអនុញ្ញាត ។

២- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយនឹងអាជ្ញាធរដែនដីខេត្ត ក្រុង បើកយុទ្ធនាការជាប្រចាំដើម្បីចុះចាប់ឃាត់ទុក និងប្រមូល ជាអាទិ៍ តាមលំនៅដ្ឋាន ដេប៉ូឈើ ឬគ្រឿងសង្ហារឹម កន្លែងលក់ដុំ ឬលក់រាយ រោងសន្និធិ មូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬនៅទីកន្លែងផ្សេងទៀត នូវរណារយន្តកាត់-អារឈើ ដែលមិនបានទទួលការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) ។

៣- ចំពោះរណារយន្តកាត់-អារឈើ ដែលបានទទួលការអនុញ្ញាតរួចហើយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (រដ្ឋបាលព្រៃឈើ) និង ក្រសួងបរិស្ថាន ត្រូវចុះធ្វើការត្រួតពិនិត្យ ស្រង់ស្ថិតិ និង ចុះបញ្ជីកាឱ្យបានច្បាស់លាស់ ដើម្បីគ្រប់គ្រងតាមសមត្ថកិច្ចរៀង១ខ្លួន។

៤- ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ពន្ធ័ ត្រូវពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ដែលមានជាធរមានឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុត ជាពិសេស អំពីទោសប្បញ្ញត្តិចំពោះជនទាំងឡាយណា ដែលប្រើប្រាស់រណារយន្តកាត់-អារឈើ ដោយគ្មានការអនុញ្ញាត ឬឃុបឃិតឱ្យមានការប្រើប្រាស់រណារយន្តកាត់-អារឈើ ដោយខុសច្បាប់ ដើម្បីប្រមូលផល អនុផលព្រៃឈើ កាប់រានព្រៃឈើគ្រប់ប្រភេទ (ដីព្រៃឈើ ដីព្រៃលិចទឹក និងដីព្រៃក្នុងតំបន់ការពារធម្មជាតិ) ដើម្បីហ៊ុំព័ទ្ធយកដីធ្វើជាកម្មសិទ្ធិ។

៥- ក្រសួង ស្ថាប័នពាក់ព័ន្ធ គយ និងរដ្ឋាករ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវសហការអនុវត្តបទបញ្ជានេះក្នុងស្មារតីទទួលខុសត្រូវ និងឱ្យមានប្រសិទ្ធភាពខ្ពស់ ហើយរាយការណ៍ប្រចាំខែអំពីលទ្ធផលជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុតឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃឈើវាតយកដីធ្វើកម្មសិទ្ធិ តាមករណីជាក់ស្តែងនីមួយៗ។ កងយោធពលខេមរៈភូមិន្ទ មានភារកិច្ចជួយសហការបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ចខាងលើ។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងស៊ីជំរៅ តាមប្រពន្ធ័ផ្សព្វផ្សាយព័ត៌មាន ក្នុងរយៈពេល ៣ ខែ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានប្រតិបត្តិ គជដព
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចចំណុចទី ៥
- ឯកសារ កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
លេខ ១៩៦៣ ពណ.នតក

ភ្នំពេញថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **លីយ៉ុង អ៊ិនដាសស្ទ្រី ផៅវ័រ អេនជីនារីង**
**LYON INDUSTRIES POWER ENGINEERING Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 3055/06E** ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៦

មានទម្រង់ជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :

| | | |
|---|---|---|
| លោក | **ZHUANG LIANG** | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក | **ZHU XIANCHUN** | អភិបាល |
| លោក | **CHEN SHIJUN** | អភិបាល |
| លោក | **WANG JIAHONG** | អភិបាល |

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៤ ផ្លូវលេខ ៣១០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាយកពន្ធទំនិញ... ចែកចាយទំនិញ
-សេវារកយកកំរៃជើងសារលើ...ដឹកជញ្ជូន...
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចាម ប្រសិទ្ធ**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧១៥៨ ពណ.នតក

ភ្នំពេញថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ព្រែម ម៉ាល់ធី ~ ខូអបភើរេសិន**

**PRIME MULTI - COOPERATION Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 9004/06P** ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ទិច ហុង** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **សុខ ចាន់សុណា** " គតិយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៥៦ - ២៥៨ មហាវិថីកម្ពុជាក្រោម សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវារកយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋមន្ត្រីស្ដីទី

ក៏ម_ស៊ីផាន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ ២៧៦០ ពណ.នតក**

ភ្នំពេញថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **សុត្រមុនី ត្រេឌីង**
**SOTH MONY TRADING Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 9009/06P** ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **សុត្រ មុនី** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **លីន ចន្ធូ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៨៥ ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ័រណ អាហារណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
